# ការអនុវត្តដើម្បីឱ្យបានទទួលការគាំទ្រពីអ្នកពាក់ព័ន្ធចំពោះការធ្វើសមាហរណកម្ម

Better Care Network

## សេចក្តីសង្ខេបអំពីវីដេអូ

ការធ្វើសមាហរណកម្មកុមារចេញពី មណ្ឌលថែទាំកុមារ ទៅក្នុងសហគមន៍ និងគ្រួសារវិញ អាចជាដំណើរការដែលត្រូវជម្នះឧសគ្គជាច្រើន ហើយតម្រូវឱ្យមានការគាំទ្រយ៉ាងរឹងមាំពីពហុអ្នកពាក់ព័ន្ធ។ បរាជ័យក្នុងការទទួលបានការគាំទ្រ និងការមិនបានប្រាស្រ័យទាក់ទងឱ្យបានច្បាស់លាស់អំពីមូលហេតុដែលធ្វើឱ្យមានសមាហរណកម្ម ក៏ដូចជាដំណើរការនៃសមាហរណកម្មអាចបង្កឱ្យមានបញ្ហាជាច្រើន ដែលធ្វើឱ្យប៉ះពាល់ដល់លទ្ធផលរបស់កុមារនៅទីបំផុត។ ប៉ុន្តែដើម្បីឱ្យបានទទួលការគាំទ្រ នោះមានការងារស្មុគស្មាញជាច្រើនដែលត្រូវធ្វើ ពោលគឺមិនមែនគ្រាន់តែពិភាក្សាអំពីអ្វីជាឧត្តមប្រយោជន៍របស់កុមារតែប៉ុណ្ណោះទេ។ ការងារនេះ តម្រូវឱ្យអ្នកសង្គមកិច្ច ឬបុគ្គលិកបច្ចេកទេស ជាដំបូងត្រូវយល់អំពីកត្តាជំរុញទឹកចិត្ត និងកង្វល់ជាលក្ខណៈបុគ្គលផ្សេងៗជាច្រើន ដែលអាចខុសគ្នាពីក្រុមអ្នកពាក់ព័ន្ធមួយទៅក្រុមអ្នកពាក់ព័ន្ធមួយ ហើយត្រូវរៀបយុទ្ធសាស្ត្រការប្រាស្រ័យទាក់ទងឱ្យសមស្របទៅតាមនោះដែរ។

ក្នុងកម្រងវីដេអូដែលចែកជាពីរផ្នែកនេះ លោកស្រី នូ ដាលីន ធ្វើពិភាក្សាអំពីបទពិសោធន៍របស់ខ្លួនក្នុងការធ្វើការងារជាដៃគូជាមួយមន្ទីរសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា (មន្ទីរ ស.អ.យ) នៅក្នុងខេត្តបាត់ដំបង ដើម្បីអនុវត្តផែនការសកម្មភាពរបស់ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា (ក្រសួង ស.អ.យ) ស្តីពីការលើកកម្ពស់ការថែទាំកុមារ។ ដាលីន ផ្តោតការយកចិត្តទុកដាក់លើការរៀនសូត្ររបស់នាង ទាក់ទងជាមួយការប្រាស្រ័យទាក់ទងជាមួយនាយកមណ្ឌលកុមារកំព្រា បុគ្គលិកថែទាំកុមារ គ្រួសារ និងកុមារ ដើម្បីឈានទៅទទួលបានការគាំទ្រចំពោះសមាហរណកម្មកុមារ ដែលកំពុងរស់នៅក្នុងមណ្ឌលថែទាំ។ ដាលីន ចែករំលែកទស្សនៈយល់ឃើញទាក់ទងជាមួយចំណុចតូចៗដែលមានសារៈសំខាន់ និងភាពខុសគ្នានៃគោលវិធីសម្រាប់ក្រុមអ្នកពាក់ព័ន្ធនីមួយៗ ហើយពិភាក្សាអំពីហានិភ័យដែលអាចកើតមានចំពោះកុមារក្នុងករណីពុំបានទទួលការគាំទ្រពីក្រុមអ្នកពាក់ព័ន្ធ។

## ចំណុចពិភាក្សា៖

### ការគ្រប់គ្រងហានិភ័យ

ក្នុងខ្សែវីដេអូ ដាលីន គូសបញ្ជាក់អំពីហានិភ័យចំពោះកុមារពាក់ព័ន្ធជាមួយការធ្វើសមាហរណកម្ម ប្រសិនបើការចូលរួមរបស់អ្នកពាក់ព័ន្ធពុំត្រូវបានគ្រប់គ្រងបានល្អទេនោះ។ ក្នុងបរិបទរបស់ដាលីន ហានិភ័យទាំងនេះពាក់ព័ន្ធជាមួយសុវត្ថិភាពកុមារ ការបន្តការសិក្សា ស្ថិរភាពនៃការទុកដាក់កុមារ ទំនាក់ទំនងជាមួយឪពុកម្តាយ និងសុខុមាលភាពផ្លូវចិត្ត។

## ក្នុងបរិបទរបស់អ្នក៖

- តើមានហានិភ័យអ្វីខ្លះចំពោះកុមារក្នុងករណីបរាជ័យមិនអាចទទួលបានការគាំទ្រពីអ្នកពាក់ព័ន្ធក្នុង បរិបទកម្មវិធីរបស់អ្នក ឬការអនុវត្តផ្នែកសង្គមកិច្ចរបស់អ្នក?
- តើមានវិធានការអ្វីខ្លះដើម្បីគ្រប់គ្រង និងពិនិត្យតាមដានលើហានិភ័យទាំងនោះ?
- តើមានអ្វីខ្លះផ្សេងទៀត ដែលអាចធ្វើបានដើម្បីយល់ កាត់បន្ថយ និងអាចគ្រប់គ្រងហានិភ័យឱ្យបានកាន់តែប្រសើរ?
- តើចំណុចទាំងនេះ មានផលពាក់ព័ន្ធយ៉ាងណាខ្លះ និងការតម្រូវដូចម្តេចខ្លះចំពោះកម្មវិធី និងធនធានរបស់អ្នក?

ចំណុចពិភាក្សា៖

## សូមកំណត់ និងឆ្លើយតបចំពោះកត្តាជំរុញទឹកចិត្តរបស់អ្នកពាក់ព័ន្ធ

នៅក្នុងខ្សែវីដេអូនេះ ដាលីន ពិពណ៌នាបញ្ជាក់ថា មិនមានគោលវិធី “ទោលតែមួយដែលត្រូវសម្រាប់គ្រប់គ្នា” នៅក្នុងការប្រាស្រ័យទាក់ទងជាមួយអ្នកពាក់ព័ន្ធនោះទេ ហើយចំណុចផ្សេងគ្នា ក៏មានគោលបំណងខុសគ្នា ហើយជះឥទ្ធិពលប្លែកគ្នាទៅលើក្រុមអ្នកពាក់ព័ន្ធផងដែរ។ ឧទាហរណ៍ ដាលីន បញ្ជាក់ថា ការពិភាក្សាអំពីគោលនយោបាយ គឺមានសារៈសំខាន់ដើម្បីផ្តៀងផ្ទាត់លើតួនាទី និងសមត្ថកិច្ចរបស់អ្នកសង្គមកិច្ច ប៉ុន្តែការពិភាក្សាផ្នែកគោលនយោបាយ គឺពុំមែនជាឧបករណ៍ដ៏មានប្រសិទ្ធភាព ដើម្បីផ្លាស់ប្តូរផ្នត់គំនិតស្តីពីមណ្ឌលថែទាំកុមារឡើយ ជាពិសេសសម្រាប់ការជជែកជាមួយគ្រួសារ។ ជំនួសមកវិញ ដាលីន បញ្ជាក់ថា អ្នកចាំបាច់ត្រូវតែចាប់យកមនោសញ្ចេតនា និងអារម្មណ៍ជាលក្ខណៈបុគ្គលរបស់អ្នកពាក់ព័ន្ធនីមួយៗ ហើយប្រើប្រាស់បទពិសោធន៍ដែលពួកគាត់ធ្លាប់ជួប និងអាចយល់បាន ដើម្បីជួយពួកគាត់ឱ្យយល់អំពីទស្សនៈរបស់កុមារ។

## ក្នុងបរិបទរបស់អ្នក៖

? តើនរណាជាក្រុមអ្នកពាក់ព័ន្ធដែលអ្នកចាំបាច់ត្រូវទទួលបានការគាំទ្រពីពួកគាត់សម្រាប់ការធ្វើសមាហរណកម្មកុមារ ឬដើម្បីធានាឱ្យបានថា កុមារមានឱកាសដើម្បីទទួលបានការចិញ្ចឹមបីបាច់ក្នុងគ្រួសារ?

? តើអ្វីខ្លះដែលជំរុញទឹកចិត្តពួកគេ ហើយតើអាច (ក) ប្រើប្រាស់កត្តាជំរុញទឹកចិត្តទាំងនេះ ដោយរបៀបណា ដើម្បីបង្កើនថាមពលឆ្ពោះទៅគាំទ្រដល់សមាហរណកម្ម/ការថែទាំកុមារតាមគ្រួសារ និង/ឬ (ខ) បង្កើតឱ្យមានជាឧបសគ្គរាំងការគាំទ្រចំពោះសមាហរណកម្ម/ការថែទាំតាមគ្រួសារ?

? តើអ្នកអាចកែសម្រួលយុទ្ធសាស្ត្រប្រាស្រ័យទាក់ទងសម្រាប់ក្រុមអ្នកពាក់ព័ន្ធនីមួយៗដោយរបៀបណា ដើម្បីឱ្យឆ្លើយតបចំពោះកត្តាជំរុញទឹកចិត្ត និងកង្វល់របស់ពួកគេ? តើអ្វីខ្លះជាសារគន្លឹះក្នុងយុទ្ធសាស្ត្ររបស់អ្នក ហើយអ្វីខ្លះជាគោលបំណងសម្រាប់យុទ្ធសាស្ត្រនីមួយៗ (ពោល គឺជាមូលដ្ឋានដើម្បីបង្ហាញអំពីសមត្ថកិច្ច ភាពពាក់ព័ន្ធផ្តល់ភស្តុតាងធានាឱ្យមានភាពអនុលោមតាម អន្ទងមនោសញ្ចេតនា ផ្សារភ្ជាប់ជាមួយបទពិសោធន៍ផ្ទាល់ខ្លួន)?

? តើមានជំហានបន្ទាប់អ្វីខ្លះ ដែលអ្នកចាំបាច់ត្រូវធ្វើ ដើម្បីអភិវឌ្ឍ ឬកែសម្រួលយុទ្ធសាស្ត្រប្រាស្រ័យទាក់ទងរបស់អ្នក ហើយតើត្រូវការធនធានអ្វីខ្លះសម្រាប់អង្គភាពរបស់អ្នក?

លំហាត់៖

## សូមអភិវឌ្ឍយុទ្ធសាស្ត្រដើម្បីបង្កឱ្យមានការចូលរួមពីអ្នកពាក់ព័ន្ធ

ផ្អែកលើចំណុចពិភាក្សាខាងលើ សូមបង្កើតយុទ្ធសាស្ត្រការប្រាស្រ័យទាក់ទងដើម្បីបង្កឱ្យមានការចូលរួមពីអ្នកពាក់ព័ន្ធ (ឬចំណុចគោលសំខាន់ៗរបស់យុទ្ធសាស្ត្រ)។ សូមជ្រើសរើសអ្នកពាក់ព័ន្ធដែលពាក់ព័ន្ធជាមួយការងារអ្នកបំផុត ហើយបង្ហាញចំណុចដូចខាងក្រោមនៅក្នុងផែនការយុទ្ធសាស្ត្ររបស់អ្នក៖

- ប្រវត្តិរូបរបស់អ្នកពាក់ព័ន្ធ
- ឯកសារមគ្គុទ្ទេសក៍សម្រាប់ប្រាស្រ័យទាក់ទងផ្ទាល់មាត់ ដោយផ្តោតការយកចិត្តទុកដាក់លើសារគន្លឹះ ដើម្បីឆ្លើយតបចំពោះកត្តាជំរុញទឹកចិត្ត និងកង្វល់របស់ពួកគេ។
- ធនធានជាលាយលក្ខណ៍អក្សរដែលអ្នកអាចទៅរក យកមកប្រើ ឬបង្កើតឡើងដើម្បីផ្តល់ព័ត៌មានបន្ថែមទៀតដល់អ្នកពាក់ព័ន្ធរបស់អ្នក (ដូចជាសន្លឹកព័ត៌មានដែលផ្តល់ចម្លើយតបចំពោះសំណួរដែលគេច្រើនសួរ សន្លឹកព័ត៌មានឯកសារសង្ខេបគោលនយោបាយ។ល។)
- សម្ភារគាំទ្រដទៃទៀត ដូចជាករណីសិក្សា និងវីដេអូ ដែលអាចយកទៅប្រើប្រាស់ដើម្បីកសាងទំនុកចិត្ត ឆ្លើយតបចំពោះ